ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ០៤៦/១៣ រ.បា.ក អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែកុម្ភៈ ឆ្នាំ២០១៣ និងទិសដៅការងារ ខែមីនា ឆ្នាំ២០១៣

(ពីថ្ងៃទី ០១/០២/២០១៣ ដល់ ថ្ងៃទី ២៨/០២/២០១៣)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តន៍តាមយុទ្ធសាស្ត្រពហុវិស័យ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្តន៍ "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានអនុវត្តនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៣ នេះ មានដូចខាងក្រោម :

### I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ខែកុម្ភៈ ឆ្នាំ២០១៣ នេះ តាមរបាយការណ៍របស់អង្គភាពអនុវត្តច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន និង រាជធានី-ខេត្តចំនួន ១៣ គឺ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តស្ទឹងត្រែង ខេត្តកំពត ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ ខេត្តមណ្ឌលគិរី ខេត្តប៉ៃលិន និង ខេត្តឧត្តរមានជ័យ ដែលបានធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀនជាក់ស្តែងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន បានបង្ហាញថា សកម្មភាពចរាចរជួញដូរចែកចាយ និងប្រើប្រាស់គ្រឿងញៀននៅតែបន្តកើតមាននៅតាមមូលដ្ឋានខាងលើ ។ គ្រឿងញៀនទាំងនោះ ភាគច្រើនបាននាំពីតំបន់ត្រីកោណមាស ហើយហូរចូលមកកម្ពុជា តាមច្រកនៃបណ្តាខេត្តនៅភាគឦសាន (ច្រករបៀងនៃខេត្តស្ទឹងត្រែង និង ខេត្តព្រះវិហារ) ។

ជាមួយនេះក៏មានការនាំ កូកាអ៊ីន ដាក់បង្កប់ក្នុងកញ្ចប់បញ្ញើរប៉ាសនៃក្រុមហ៊ុន DHL ពីកម្ពុជាទៅកាន់ប្រទេសស៊ុយអែត បានកើតឡើង១លើក ត្រូវបានមន្ទីរប្រឆាំងគ្រឿងញៀនរកឃើញនាថ្ងៃទី១៤/០១/២០១៣ និងកំពុងធ្វើការស្រាវជ្រាវ ។

### II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

#### ១. អំពីការងារដឹកនាំនៃស្ថាប័នកំពូលរបស់ថ្នាក់ជាតិ

នៅក្នុងខែកុម្ភៈនេះ ថ្នាក់ដឹកនាំនៃស្ថាប័នកំពូលរបស់ថ្នាក់ជាតិ បានដឹកនាំធ្វើជាត្រីវស័យក្នុងការអនុវត្តការងារប្រយុទ្ធ



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone , Fax: (855) 23 721 648, Fax: (855) 23 727 529
E-mail: info@nacd.gov.kh, Website: www.nacd.gov.kh

ប្រឆាំងគ្រឿងញៀន ជាអាទិ៍ :

**រាជរដ្ឋាភិបាល** ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ :

- បានធ្វើការណែនាំតាមរយៈសារាចរណែនាំ ស្តីពីការរៀបចំ "ទិវាវប្បធម៌ជាតិ ៣ មីនា" លើកទី១៥ ឆ្នាំ២០១៣ ដែលនៅក្នុងចំណុចទី៨ សម្តេចនាយករដ្ឋមន្ត្រីបានធ្វើការណែនាំដល់អាជ្ញាធរដែនដីរាជធានី-ខេត្ត ចូលរួមគាំទ្រទិវានេះនិងបង្កលក្ខណៈឱ្យមានកម្មវិធីសម្តែងសិល្បៈ ទស្សនីយភាពអប់រំពីការចូលរួមថែរក្សាការពារសម្បត្តិវប្បធម៌, ការលើកស្ទួយសីលធម៌សង្គម ព្រមទាំង **"ការអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀន"** និងគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ ។
- បានអនុញ្ញាតជាគោលការណ៍ឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ និងលើកទិសដៅការងារ ឆ្នាំ២០១៣ នាថ្ងៃទី១២-១៣ ខែមីនា ឆ្នាំ២០១៣ ។

**កាកបាទក្រហមកម្ពុជា**

- ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នាថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ បានធ្វើពិធីចែកអំណោយដល់អ្នកផ្ទុកមេរោគអេដស៍ ជនពិការ កុមារកំព្រា និងចាស់ជរាគ្មានទីពឹង នៅក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដោយបានបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនជាចំណេះដឹងទូទៅសម្រាប់ពួកគាត់យកទៅផ្សព្វផ្សាយអប់រំបន្តនៅតាមមូលដ្ឋានសហគមន៍[១] ។

## ២. ការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន :

- បានអនុញ្ញាតឱ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រុមហ៊ុន ប៊ី.ខេ.អេ (B.K.A Entertainment) រៀបចំកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្រោមប្រធានបទ " Just Say No to Drugs" នៅក្នុងវិទ្យាល័យចំនួន ១០ ក្នុងរាជធានីភ្នំពេញ ។
- បានគាំទ្រនិងអនុញ្ញាតឱ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមសកម្មភាពផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ជាមួយក្រុមហ៊ុន O range ក្នុងកម្មវិធីប្រគំតន្ត្រី "ឆ្នាំសន្តិភាព" នៅខេត្តចំនួន ១២ ។
- បានណែនាំឱ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមចំណែកតាមគ្រប់រូបភាព ដើម្បីអនុវត្តសារាចរណែនាំ ស្តីពីការរៀបចំទិវា **"វប្បធម៌ជាតិ ៣ មីនា ២០១៣"** ឱ្យមានប្រសិទ្ធភាពខ្ពស់ ។
- បានអនុញ្ញាត ក្នុងនាមប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងទទួលជួយនាយករដ្ឋមន្ត្រី លើការងារប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចូលជួបធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃដំណើរទស្សនកិច្ចទៅកាន់ខេត្តយូណាន ប្រទេសចិន (១១/០១/២០១៣) ។
- បានណែនាំឱ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រៀបចំកិច្ចប្រជុំក្រុមការងាររៀបចំលិខិតបទដ្ឋានគតិយុត្តិ ដើម្បី

[១] ធ្វើនៅឃុំសន្លុង ស្រុកខ្សាច់កណ្តាល ថ្ងៃទី២៥/០១/២០១៣ (របាយការណ៍ ខែមករា ២០១៣ របស់ស្នងការដ្ឋាននគរបាលខេត្តកណ្តាល)

ពិនិត្យលើខ្លឹមសារសេចក្តីព្រាង អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី២៦/០២/២០១៣) ។

- បានណែនាំឱ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីត្រួតពិនិត្យរបាយ-ការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ និងទិសដៅការងារ ឆ្នាំ២០១៣ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ ។
- បានត្រៀមលក្ខណៈរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ និងទិសដៅការងារ ឆ្នាំ២០១៣ នាថ្ងៃទី១២-១៣ ខែមីនា ឆ្នាំ២០១៣ ។

ទន្ទឹមនេះ ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែមករាឆ្នាំ២០១៣កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តវិធានការពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

## ក. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួង ស្ថាប័នជាសមាជិកទាំងអស់ បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយតាមកម្មវិធីប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និង ប្រចាំខែ **ដូចមានសកម្មភាពការងារជាក់ស្តែងនៅក្នុងឧសម្ព័ន្ធទី១ ។ ដោយឡែក អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :**

- តាមរយៈកម្មវិធីប្រចាំខែ ដែលផ្តល់ដោយស្ថានីយ៍ទូរទស្សន៍ ស៊ី.ធី.អិន (C.T.N) និង ស៊ី.អិន.ស៊ី (C.N.C) បានផ្តល់នូវកិច្ចសម្ភាសន៍ក្នុងកម្មវិធី សភាអ៊ីនធឺណែត ស្តីពី "អត្តសញ្ញាណនិងឥទ្ធិពលនៃគ្រឿងញៀន" កាលពីថ្ងៃទី២៧/០២/២០១៣ ។
- បានបន្តកិច្ចសហការជាមួយស្ថានីយទូរទស្សន៍បាយ័នរៀបចំកម្មវិធីប្រដាល់ដណ្តើមខ្សែក្រវ៉ាត់របស់អាជ្ញាធរជាតិដោយមានរៀបចំសំដែងនូវឈុតខ្លីៗជាសារអប់រំពីបញ្ហាគ្រឿងញៀន ។
- ចូលរួមប្រជុំពិភាក្សាអំពីដំណើរការរៀបចំការប្រឡងមហោស្រពតន្ត្រី ចម្រៀងសម័យ ថ្នាក់ជាតិឆ្នាំ២០១៣ ដែលរៀបចំដោយក្រសួងព័ត៌មាន ដើម្បីបញ្ជ្រាបការងារផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ទៅចូលរួមកិច្ចប្រជុំដៃគូអង្គការ IOGT-NTO Movement របស់ប្រទេសស៊ុយ-អែត នៅទីក្រុងឈៀងម៉ៃ ប្រទេសថៃ កាលពីថ្ងៃទី០៤-០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ដើម្បីពិនិត្យ និងចែករំលែកបទពិសោធន៍ឱ្យគ្នាទៅវិញទៅមក ពីការអនុវត្តគម្រោងក្នុងឆ្នាំ២០១០-២០១២ និង រៀបចំផែនការ ៣ ឆ្នាំបន្តសម្រាប់ឆ្នាំ២០១៤-២០១៦ ។
- បានបន្តកិច្ចសហការជាមួយ ស្ថានីយទូរទស្សន៍បាយ័ន រៀបចំកម្មវិធីប្រដាល់ដណ្តើមខ្សែក្រវ៉ាត់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២លើក ( ថ្ងៃទី០៧ និង ២៣ ខែកុម្ភៈ ២០១៣) ។
- បានសហការជាមួយ :
    - ✓ ក្រុមហ៊ុន អូ.រ៉េង (O Range) បញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ទៅក្នុងកម្មវិធី

ប្រគំតន្ត្រី "ឆ្នាំសន្តិភាព" នៅខេត្តស្វាយរៀង (១៦-១៧/០២/២០១៣) ។

- ✓ សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តកំពង់ឆ្នាំង និងទូរទស្សន៍ហង្សមាស បញ្ជ្រាបខ្លឹមសារផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីប្រគំតន្ត្រី "ខារាបាវ" នៅខេត្តកំពង់ឆ្នាំង (១៧/០២/២០១៣) ។
- ✓ សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រះវិហារ និងក្រុមហ៊ុនហួមមេឌា ធ្វើការបញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីប្រគំតន្ត្រី "តារាបែតងកម្ពុជា" (២២-២៥/២/២០១៣) ។
- ✓ សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តកំពង់ធំ និងទូរទស្សន៍ហង្សមាស បញ្ជ្រាបខ្លឹមសារផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីប្រគំតន្ត្រី "ខារ៉ាបាវ" នៅទីរួមខេត្តកំពង់ធំ (២៤/០២/២០១៣) ។

- សហការជាមួយអគ្គនាយកដ្ឋានទូរទស្សន៍បាយ័ន ដើម្បីបញ្ជ្រាបខ្លឹមសារស្តីពី ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ទៅក្នុងកម្មវិធីតន្ត្រីស្រុកស្រែ នៅខេត្តតាកែវ ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបញ្ហាគ្រឿងញៀន ដែលបានអនុវត្តដោយក្រសួង-ស្ថាប័នរដ្ឋជាសមាជិក , ក្រសួង ស្ថាប័នរដ្ឋ ដែលមិនមែនជាសមាជិក អ.ជ.ប.គ.ញ (អគ្គិសនីកម្ពុជា), អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន ៧ គឺ ខេត្តព្រះវិហារ ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តប៉ៃលិន និង ខេត្តកំពង់ស្ពឺ នៅក្នុងខែកុម្ភៈឆ្នាំ២០១៣ នេះ មានមហាជនចូលរួមសរុប ***១២៣.៧៧៦*** នាក់ **ដូចមាននៅក្នុងឧបសម្ព័ន្ធទី១** ។

## ***ខ. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន***

ក្នុងខែកុម្ភៈ ឆ្នាំ២០១៣នេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាពនិងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

### ***ខ.១. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន***

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៤៤** ករណី
- **ជនសង្ស័យ** ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ឃាត់ខ្លួន **៧៦** នាក់
- **ចាប់តាមដីកា មាន** ៥ ដីកា = ៥ នាក់ (ស្រី ២ នាក់) ជនជាតិខ្មែរ

ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានឃាត់ខ្លួន **៧៦** នាក់ ខាងលើ មានប្រុស ៥៩ នាក់ ស្រី ១៧ នាក់ ក្នុងនោះ ជនជាតិ **ខ្មែរ** ៦៥ នាក់ (ស្រី ១២ នាក់) , **វៀតណាម** ៩ នាក់ (ស្រី ៥ នាក់) , ថៃ ១ នាក់ (ប្រុស), ចិន ១ នាក់ (ប្រុស) ។ ត្រូវបានសមត្ថកិច្ច កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

- **វត្ថុតាងគ្រឿងញៀនចាប់យក** រួមមាន មេតំហ្វេតាមីន (WY) ៨១៧ គ្រាប់, មេតំហ្វេតាមីនក្រាមម្សៅ (Ice) ៨៩៨,៦១ ក្រាម , ហេរ៉ូអ៊ីន ០,០៩ ក្រាម , កូកាអ៊ីន ៥០ ក្រាម ។

- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ចាប់យក** រួមមាន :

រថយន្ត ១ គ្រឿង, ម៉ូតូ ១៤ គ្រឿង, ប្រាក់កម្ពុជា ១.៦៤០.០០០ រៀល, ប្រាក់អាមេរិក ៣.៩១០ ដុល្លារ, ប្រាក់ថៃ ៩០០ បាត, ប្រាក់វៀតណាម ២.៩០៨.៩០០ ដុង ។

### ៩.២. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសុខាភិបាល ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ និងវត្ថុធាតុដើម និងឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលនៅក្នុង ខែកុម្ភៈ ឆ្នាំ២០១៣ មានដូចខាងក្រោម :

- សារធាតុគីមីពិតជា គីឡូក្រាម ចំនួន ៦.១៦៦.៤៧២ Kgs និង ២៤០ លីត្រ
- វត្ថុធាតុដើម និងឱសថប៉ះពាល់ប្រព័ន្ធសសៃប្រសាទ ចំនួន ១ Kg , ៥១៤ g , ២.៤៦១ mg ។

### ៩.៣. ការងារកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តច្បាប់នានា នៅក្នុងខែកុម្ភៈនេះ សរុបបានចំនួន ៥៨ ករណី = ៧៣ សំណាក (សំណាក**អវិជ្ជមានសារធាតុញៀន** ៣ សំណាក = ៤ % និង សំណាក**វិជ្ជមានសារធាតុញៀន** ៧០ សំណាក = ៩៥ %) ក្នុងនោះគឺ ៖

-មេតំហ្វេតាមីនក្រាមម្សៅ ៤៦ សំណាក = ៦៣ %    -មេតំហ្វេតាមីនគ្រាប់ ២២ សំណាក = ៣០ %

-កញ្ឆា ១ សំណាក = ១ %    -កូកាអ៊ីន ១ សំណាក = ១ %

(**ការបែងចែកលំអិតនៃការងារកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន មាននៅក្នុងឧបសម្ព័ន្ធ ទី២**)

## គ. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់ទីជំរាជីវៈ និងសមាហរណកម្ម

- បានផ្តល់ការគាំទ្រដល់ អង្គការ FHI360 និងសកលវិទ្យាល័យ កាលីហ្វ័រញ៉ា សាន់ហ្វ្រាន់ស៊ីស្កូ ធ្វើកម្មសិក្សាស្រាវជ្រាវក្នុងចំណោមស្ត្រីបម្រើការងារនៅទីកន្លែងផ្តល់សេវាកម្សាន្តសប្បាយនៅកម្ពុជា ដើម្បីឈានទៅអនុវត្តន៍គម្រោងស្តីពី "អន្តរាគមន៍ថ្មី ចំពោះស្ត្រីប្រើគ្រឿងញៀនប្រភេទ ATS ដែលបម្រើការនៅទីកន្លែងផ្តល់សេវាកម្សាន្តសប្បាយ" ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញចូលរួមកិច្ចប្រជុំ ក្រុមការងាររួមរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីការងារមេរោគអេដស៍/ជំងឺអេដស៍ ដើម្បីរៀបចំបញ្ច្រាបខ្លឹមសារពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន (២២/០២/២០១៣) តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

## ឃ. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

- **កិច្ចការក្នុងប្រទេស** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :
    - បានរៀបចំកិច្ចប្រជុំគណ:កម្មការប្រឹក្សាយោបល់គម្រោង PATROL ដើម្បីពិភាក្សាពីការរៀបចំផែនការសកម្មភាពអនុវត្តន៍គម្រោង PATROL សម្រាប់ឆ្នាំ២០១៣ ។

- បានបើកវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ថ្មី) ដល់មន្ត្រីមន្ទីរប្រឆាំងគ្រឿងញៀន និងមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សរុបចំនួន ៤៥ រូប កាលពីថ្ងៃទី១៨-២២ ខែកុម្ភៈ ឆ្នាំ២០១៣ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។
- បានចូលរួមធ្វើបទបង្ហាញ ក្នុងសិក្ខាសាលាបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការអង្កេត និងការត្រួតពិនិត្យសារធាតុបំផ្លាញស្រទាប់អូហ្សូន កាលពីថ្ងៃទី២១-២២/០២/២០១៣ តាមការស្នើសុំរបស់ក្រសួងបរិស្ថាន នៅខេត្តស្វាយរៀង ។
- បានរៀបចំកិច្ចប្រជុំពិភាក្សា លើកទី២ ស្តីពីការពង្រឹងសមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ ។ អង្គប្រជុំបានសម្រេចដូចតទៅ :
  ១. អង្គការដៃគូបានគាំទ្រ និងធ្វើការពិនិត្យលទ្ធភាពក្នុងការចូលរួមរបស់ខ្លួន ដើម្បីជួយលើការពង្រឹងសមត្ថ-ភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ។
  ២. មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ត្រូវពិចារណាបន្ថែមអំពីការងារប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន ឱ្យបានទូលំទូលាយ និងត្រូវពង្រីកបន្ថែមនូវសូចនាករចាំបាច់មួយចំនួន ពិសេសទិន្នន័យពាក់ព័ន្ធនឹងការកាត់បន្ថយគ្រោះថ្នាក់ និងជំងឺអេដស៍ ។
  ៣. មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ត្រូវបង្កើតឡើងនូវទម្រង់នៃការប្រមូលទិន្នន័យឱ្យមានគំរូឯកភាពមួយសម្រាប់ដាក់ឱ្យអនុវត្ត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងអង្គការ ស្ថាប័នពាក់ព័ន្ធ ប្រយោជន៍ឱ្យការងារប្រមូល និងគ្រប់គ្រងទិន្នន័យមានលក្ខណៈរួម និងសមស្របតាមវិទ្យាសាស្ត្រ ។
  ៤. ពិចារណាឡើងវិញពីរចនាសម្ព័ន្ធ និងមន្ត្រីបម្រើការងារនៅក្នុងមជ្ឈមណ្ឌលឱ្យបានសមស្រប ។
  ៥. មន្ត្រីជំនាញរបស់មជ្ឈមណ្ឌល ត្រូវបន្តការងារជាមួយអង្គការដៃគូពាក់ព័ន្ធ ដើម្បីបញ្ចប់នូវផែនការសកម្ម-ភាពលំអិត ទៅតាមសកម្មភាពការងារអាទិភាពរបស់មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ។
  ៦. នឹងរៀបចំកិច្ចប្រជុំម្តងទៀត នៅពេលឯកសាររៀបចំរួច ។

ក្រៅពីនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញបានផ្តល់សៀវភៅច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់ :

- ✓ សិក្ខាកាម ដែលបានទទួលការបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំនួន ៦០ ច្បាប់ ។
- ✓ មន្ត្រីនគរបាល នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ ចំនួន ១៥០ ច្បាប់ និងតេស្តទឹកម៉ូត្រចំនួន ២០ តេស្ត ។

## ខ. *កិច្ចសហប្រតិបត្តិការអន្តរជាតិ*

ខែកុម្ភៈឆ្នាំ២០១៣នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ មានដូចខាងក្រោម :

**ខ.១. ការងារក្នុងប្រទេស** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

- បានចាត់បញ្ជូនមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញទទួលបន្ទុកកិច្ចការ CLV, CLMV និង ACMECS ទៅចូលរួមកិច្ចប្រជុំត្រៀមសម្រាប់ការចូលរួមកិច្ចប្រជុំកំពូល CLV លើកទី៧, CLMV លើកទី៦ និង ACMECS លើកទី៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម (២១/០២/២០១៣) ។

**ង.២. ការងារក្រៅប្រទេស** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

- បានទៅចូលរួមកិច្ចប្រជុំ ទ្វេភាគី កម្ពុជា-ថៃ លើកទី៧ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន នៅខេត្តប្រាឈូបឃីរីខាន ប្រទេសថៃ (២០-២៣/០២/២០១៣) ។ សមាសភាពអញ្ជើញទៅចូលរួមសរុបចំនួន ១៨ រូប រួមមាន តំណាងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ៤ រូប, តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១ រូប, តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ ១ រូប, តំណាងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ចំនួន ២ រូប ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ទៅចូលរួមសន្និសីទ ស្តីពីការអនុវត្តច្បាប់គ្រឿងញៀន នៅតំបន់អាស៊ីប៉ាស៊ីហ្វិក លើកទី១៨ (18th Asia-pacific Drug Enforcement Conference) កាលពីថ្ងៃទី២៥-២៧/០២/២០១៣ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ទៅចូលរួមកិច្ចប្រជុំមន្ត្រីសម្របសម្រួលគម្រោង H15 ដើម្បីពិនិត្យលើលទ្ធផលការងារដែលបានអនុវត្តកន្លងមក និងអំពីការរៀបចំកិច្ចប្រជុំ MOU ថ្នាក់រដ្ឋមន្ត្រី នៅទីក្រុងរ៉ង់ហ្គូន សហភាពមីយ៉ាន់ម៉ា (២៥-២៦/០២/២០១៣) ។

**ដោយឡែក :**

- **ខេត្តព្រៃវែង** តំណាងស្នងការដ្ឋាននគរបាលខេត្ត បានជួបប្រជុំជាមួយយោធាការពារព្រំដែនច្រកទ្វារអន្តរជាតិឃិនបា ខេត្តដុងថាប់ (វៀតណាម) ដើម្បីប្រជុំផ្លាស់ប្តូរសភាពការណ៍គ្នាទៅវិញទៅមក (២០/១២/២០១២) ។
- **ខេត្តកំពង់ចាម** ស្នងការនៃស្នងការដ្ឋាននគរបាលខេត្ត បានជួបប្រជុំជាមួយស្នងការដ្ឋាននគរបាលខេត្តប៊ិញហ្វឿក ដើម្បីផ្លាស់ប្តូរសភាពការណ៍គ្នាទៅវិញទៅមក (២២/០១/២០១៣) ។

***ការងារផ្សេងៗ :***

***អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :***

- បានរៀបចំកិច្ចប្រជុំ ក្រុមការងាររៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ដើម្បីពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- បានរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យរបាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ និងលើកទិសដៅការងារ ឆ្នាំ២០១៣ ។

# III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែមីនា ឆ្នាំ២០១៣

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តន៍ទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

**១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន**

១.១. ស្នើសុំទៅក្រសួងយុត្តិធម៌ ដើម្បីផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធី សភា អ៊ីនធឺណែត នៃស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន និងស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី អំពី ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ថ្ងៃទី២៧/០៣/២០១៣។

១.២. ត្រៀមចូលរួមក្នុងពិធីផ្សព្វផ្សាយសៀវភៅស្តីពី "ការអប់រំពីជំងឺអេដស៍" ទៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងចូលរួមជាអ្នកសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការអប់រំពីជំងឺអេដស៍ ទាក់ទងនឹងប្រធានបទគ្រឿងញៀន នាថ្ងៃទី០៤/៣/២០១៣ តាមការអញ្ជើញរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

១.៣. ត្រៀមធ្វើបទបង្ហាញស្តីពីគ្រឿងញៀនដល់និស្សិត នៃសកលវិទ្យាល័យឯកជននៃកម្ពុជា ( ថ្ងៃ០៥/៣/២០១៣) ។

១.៤. ត្រៀមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រុមហ៊ុន ប៊ី.ខេ.អេ (BKA Entertainment) រៀបចំកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់ និងផលប៉ះពាល់នៃគ្រឿងញៀន ក្រោមប្រធានបទ " Just Say No to Drugs" នៅក្នុងវិទ្យាល័យចំនួន ១០ ក្នុងរាជធានីភ្នំពេញ ។

១.៥. បន្តចូលរួមសកម្មភាពផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និង គ្រោះថ្នាក់នៃគ្រឿងញៀន ជាមួយក្រុមហ៊ុន O range ក្នុងកម្មវិធីប្រគំតន្ត្រី "ឆ្នាំសន្តិភាព" នៅខេត្តចំនួន ១០ ។

១.៦. ត្រៀមផ្តល់បទសម្ភាសន៍ ជាមួយវិទ្យុអាស៊ីសេរី អំពីលទ្ធផលនៃកិច្ចប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន និងការគ្រប់គ្រងមណ្ឌលព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ( ០៥ ខែមីនា ឆ្នាំ២០១៣) ។

១.៧. បន្តរៀបចំកម្មវិធីប្រដាល់ដណ្តើមខ្សែក្រវាត់ពានរង្វាន់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅស្ថានីយទូរទស្សន៍បាយ័ន ដើម្បីបញ្ជ្រាបការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៨. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៩. បន្តកិច្ចសហការជាមួយកម្មវិធីពេញនិយមតាមបណ្តាស្ថានីយ វិទ្យុ ទូរទស្សន៍ កម្មវិធីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីបញ្ជ្រាបចំណេះដឹងពីបញ្ហាគ្រឿងញៀន ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. បន្តកិច្ចសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធ្វើការស្រាវជ្រាវជនល្មើសជនជាតិថៃ ៣ នាក់ ពាក់ព័ន្ធនឹងគ្រឿងញៀន តាមការស្នើសុំរបស់ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ។

២.២. សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីធ្វើការស៊ើបអង្កេតស្រាវជ្រាវ ករណីជនជាតិខ្មែរពីរនាក់ពីបទជួញដូរគ្រឿងញៀនឆ្លងដែន ដែលត្រូវក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ឃាត់ខ្លួនកាលពីថ្ងៃទី០៧/០១/២០១៣ ( ១នាក់) និងនៅថ្ងៃទី១៥/០១/២០១៣ ( ១នាក់) ។

២.៣. រៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរប្រឆាំងគ្រឿងញៀន និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀតលើសេចក្តីព្រាងស្តីពី យន្តការនិងប្រព័ន្ធចែករំលែកព័ត៌មានពាក់ព័ន្ធនឹងការត្រួតពិនិត្យសារធាតុគីមី ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. សហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ដើម្បីជំរុញការអនុវត្តកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ និងជំរុញដំណើរការរៀបចំបង្កើតនិងពង្រីកបន្ថែមសេវាព្យាបាល អ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ក្នុងប្រព័ន្ធសុខាភិបាលឱ្យបានឆាប់រហ័ស ។

៣.២. សហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំឯកសារដែលពាក់ព័ន្ធនឹងការបង្ការ ការថែទាំ និងព្យាបាលបន្ត និង ស្តារនីតិសម្បទាចិត្ត-សង្គម ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ។

៣.៣. រៀបចំយន្តការ និងបែបបទសម្រាប់ការអនុវត្តកម្មវិធី ម្ជុល/ស៊ីរ៉ាំង តាមប្រព័ន្ធសុខាភិបាល ។

៣.៤. បន្តការផ្តល់សេវាថែទាំ ព្យាបាល និងផ្តល់របបឧបត្ថម្ភដល់អ្នកញៀនគ្រឿងញៀនដែលកំពុងសម្រាកព្យាបាល នៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ។

៣.៥. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ជំរុញការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

៣.៦. រៀបចំឯកសារគោលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៤.១. ត្រៀមកិច្ចសហការសម្របសម្រួលជាមួយក្រសួងការពារជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់កងកម្លាំងឈរជើងនៅតាមតំបន់ព្រំដែន នៃកងយោធពលខេមរភូមិន្ទ ។

៤.២. បន្តរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន តាមប្រព័ន្ធកុំព្យូទ័រ (កម្មវិធី CBT) ។

៤.៣. បន្តសហការជាមួយបណ្ឌិត្យសភានគរបាលកម្ពុជា រៀបចំឯកសារបណ្តុះបណ្តាលមន្ត្រីនគរបាលនៅតាមភូមិភាគ ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

៤.៤. បន្តកិច្ចសហការជាមួយអង្គការជាដៃគូពាក់ព័ន្ធ លើការងារពង្រឹងសមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ត្រៀមរៀបចំទទួលគណៈប្រតិភូ ការិយាល័យនាយករដ្ឋមន្ត្រី ប្រទេសប្រ៊ុយណេ ដែលអញ្ជើញមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា (០១/៣/២០១៣) ។

៥.២. សម្របសម្រួលឱ្យមានការផ្លាស់ប្តូរដំណើរទស្សនកិច្ច នៃថ្នាក់ដឹកនាំស្ថាប័នត្រួតពិនិត្យគ្រឿងញៀន នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ។

៥.៣. ត្រៀមរៀបចំដំណើរទស្សនកិច្ច សម្រាប់គណៈប្រតិភូ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅទស្សនកិច្ចនៅ ខេត្តយូណាន ប្រទេសចិន ។

៥.៤. រៀបចំកិច្ចប្រជុំ "កម្ពុជា-ថៃ ស្តីពីកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន នាថ្ងៃទី ១៤/៣/២០១៣ នៅរាជធានីភ្នំពេញ (តាមផែនការសកម្មភាពគម្រោង PATROL របស់អង្គការ UNODC សម្រាប់កម្ពុជាក្នុងឆ្នាំ២០១៣) ។

៥.៥. បន្តកិច្ចសហការជាមួយអ្នកសម្របសម្រួលគម្រោង របស់អគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ដើម្បីពង្រឹងសមត្ថភាពការិយាល័យទំនាក់ទំនងព្រំដែន នៅតាមដងទន្លេមេគង្គ ។

៥.៦. រៀបចំកម្រងសំណួររបាយការណ៍សម្រាប់ឆ្នាំ២០១២ ស្តីពី The Working of the International Drug Control Treaties and Measuring Progress of the Plan of Action and the Political Declaration តាមការស្នើសុំរបស់ ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្ម នៃអង្គការសហប្រជាជាតិ (UNODC) ។

៥.៧. ត្រៀមចូលរួមប្រជុំអ្នកគ្រប់គ្រងស៊ើបអង្កេតនៅបណ្ឌិតសភាអនុវត្តច្បាប់អន្តរជាតិ (ILEA) នាថ្ងៃទី១៨-២២/៣/២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ ។

៥.៨. សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីទទួលសម្ភារៈដែលបានជួយដោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនចិន (NNCC) ។

ក្រៅពីទិសដៅការងារខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានដូចជា :

- ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ និងទិសដៅការងារឆ្នាំ២០១៣ ។
- បន្តរៀបចំវគ្គបណ្តុះបណ្តាល ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ( ថ្មី) ។
- បន្តសហការជាមួយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដំណើរការរៀបចំបញ្ចូល ផ្ទៀងផ្ទាត់ និងវិភាគទិន្នន័យអ្នកប្រើប្រាស់គ្រឿងញៀន ក្នុងការសិក្សា ការអង្កេតរកអត្រា ប្រេវ៉ាឡង់មេរោគអេដស៍ និងឥរិយាបថប្រព្រឹត្តប្រឈមគ្រោះថ្នាក់ និងការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀន នៅកម្ពុជា ។
- បន្តការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ជំរុញការរៀបចំផែនការសកម្មភាពរបស់នាយកដ្ឋាននីមួយៗ សម្រាប់ឆ្នាំ២០១៣ ។

អគ្គលេខាធិការ

ឧត្តមសេនីយ៍ឯក យូ_ស៊ុនឡុង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ឯកឧត្តម កៅ ខុនជាក់ អនុប្រធាន អ.ជ.ប.គ.ញ
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន
"ដើម្បីជូនជ្រាប"
-ក្រសួង សមាជិក អ.ជ.ប.គ.ញ
-ក្រសួងផែនការ
-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីមុខការ"
-ឯកសារ